| លេខរៀង | វគ្គបណ្តុះបណ្តាល | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ចំនួនថ្ងៃ | តម្លៃ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សុខភាព និងសុវត្ថិភាពការងារ | ២៥_២៦ | | | | | | ១២_១៣ | | | | ១៥_១៦ | | ២ | $ ៦៥ |
| ២ | ការបណ្តុះបណ្តាលពីការណែនាំកម្មករដំបូង | | | ៣_៤ | | | | | | | | | ១៣_១៤ | ២ | $ ៦៥ |
| ៣ | ជំនាញចរចា | | | | ២០ | | | | ៩ | | | | | ១ | $ ៣៥ |
| ៤ | ការយល់ដឹងពីយេនឌ័រ | | | | | ២៥ | | | | | | | | ១ | $ ៣៥ |
| ៥ | ការគ្រប់គ្រងចំរុះនៅកន្លែងធ្វើការ | | | | | | ១៥ | | | | | | | ១ | $ ៣៥ |
| ៦ | កិច្ចសហការនៅកន្លែងធ្វើការ | | | ៣០_៣១ | | | ២៩_៣០ | | | ១៣_១៤ | | | | ២ | $ ៦៥ |
| ៧ | ច្បាប់ការងារ | | | | | | | ២៦_២៧ | | | | | | ២ | $ ៦៥ |
| ៨ | ផលិតកម្មស្អាត | | | | | | | | ៣០_៣១ | | | ២៩_៣០ | | ២ | $ ៦៥ |
| ៩ | ការបណ្តុះបណ្តាលអំពីពិការភាព | | | | | | | | | | ១១ | | ២៧ | ១ | $ ៣៥ |
| ១០ | ការគ្រប់គ្រងធនធានមនុស្ស | | | | | | | | | | ២៥_២៦ | | | ២ | $ ៦៥ |

## ព័ត៌មានលំអិត

ដើម្បីចុះឈ្មោះ ឬទទួលបានព័ត៌មានបន្ថែមអំពីការបណ្តុះបណ្តាល និងសេវាប្រឹក្សារបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* សូមទាក់ទងមកកាន់ក្រុមផ្នែកបណ្តុះបណ្តាលតាមរយៈ

អាសយដ្ឋានផ្ទះលេខ៩ ផ្លូវ៣២២ សង្កាត់បឹងកេងកង១
ក្រុងភ្នំពេញ ប្រទេសកម្ពុជា
អ៊ីម៉េល **bfctraining@ilo.org**
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១២ ៨៤៧

ព័ត៌មានបន្ថែមក៏អាចរកបាននៅលើគេហទំព័រ :
**www.betterfactories.org**

International Labour Organization

better factories Cambodia

# កាលវិភាគបណ្តុះបណ្តាល ឆ្នាំ ២០១១



## គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា នៃអង្គការពលកម្មអន្តរជាតិ

*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* គឺជាគំរោងមួយរបស់អង្គការពលកម្មអន្តរជាតិដែលផ្តោតលើការត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ និងផ្តល់នូវការបណ្តុះបណ្តាល ក៏ដូចជាសេវាប្រឹក្សា ដើម្បីធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ និងផលិតភាពនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា តាមរយៈការចូលរួមជាមួយដៃគូពាក់ព័ន្ធនានាដូចជារដ្ឋាភិបាល សហជីព និងអ្នកបញ្ជាទិញអន្តរជាតិ។

## សេវាបណ្តុះបណ្តាល និងកែលំអ

ចាប់តាំងពីឆ្នាំ២០០៣មក *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*បានជួយឱ្យរោងចក្រជាច្រើនដំណើរការកាន់តែមានប្រសិទ្ធភាពការងារជាងមុនតាមរយៈការផ្តល់កម្មវិធីបណ្តុះបណ្តាលដែលមានលក្ខណៈចូលរួម និងសហការរវាងថ្នាក់គ្រប់គ្រង និងកម្មករនិយោជិត ព្រមទាំងការបង្រៀនដោយការអនុវត្តន៍ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់រោងចក្រនីមួយៗដើម្បីធ្វើការកែលម្អប្រកបដោយនិរន្តរភាព។

ភាពអព្យាក្រិត្យ គឺជាគុណតម្លៃមួយរបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលតែងតែប្រកាន់ខ្ជាប់នៅគ្រប់សកម្មភាពការងារ។ គ្រូបណ្តុះបណ្តាលរបស់យើងប្រើវិធីសាស្ត្រ ដែលធ្វើឱ្យតំណាងថ្នាក់គ្រប់គ្រង និងតំណាងកម្មករនិយោជិតទទួលបានចំណេះដឹងពិតប្រាកដ ហើយយកចំណេះដឹងនេះទៅអនុវត្ត តាមរយៈការដោះស្រាយរួមគ្នានូវបញ្ហាដែលកើតមាន។ វិធីសាស្ត្រនេះជំរុញឱ្យមានកិច្ចពិភាក្សាមួយដើម្បីដោះស្រាយបញ្ហាប្រឈមដ៏ជាក់លាក់របស់រោងចក្រ។ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ជឿជាក់ថា វិធីសាស្ត្រនេះមានសារៈប្រយោជន៍ចំពោះការកែលំអប្រកបដោយនិរន្តភាព។

បច្ចេកទេសបង្រៀនរបស់*គំរោងរោងចក្រកាន់តែប្រសើនៅកម្ពុជា* រួមបញ្ចូលគំរូអនុវត្តន៍ល្អនានា ដោយមានកិច្ចពិភាក្សា និងការសម្តែងតួដែលរៀបចំឡើងដើម្បីស្វែងរកឱ្យឃើញនូវបញ្ហាជីវិតពិតរបស់អ្នកចូលរួម និងជួយពួកគេឱ្យយល់ពីវិធីដើម្បីអនុវត្តនូវអ្វីដែលពួកគេបានរៀនសូត្រនៅក្នុងកិច្ចការងារប្រចាំថ្ងៃរបស់ពួកគេ។

ការបណ្តុះបណ្តាលមានការផ្សាភ្ជាប់ដោយផ្ទាល់ទៅនឹងការធ្វើឱ្យប្រសើរនូវផលិតភាព។ហេតុនេះហើយ ការវិនិយោគទុនទៅលើការបណ្តុះបណ្តាល គឺមានសារៈសំខាន់ចំពោះរោងចក្រនីមួយៗ ដែលមានបំណងចង់ពង្រឹងនូវកម្លាំងពលកម្មរបស់ខ្លួន និងបង្កើននូវផលិតផលជាមួយនឹងការចំណាយតិចជាងមុន។ នេះគឺជាកត្តាមួយដ៏សំខាន់ដើម្បីរក្សាបាននូវសមត្ថភាពប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចសកលលោក។ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*ផ្តល់ឱ្យនូវឯកសារបណ្តុះបណ្តាលជាច្រើនផ្សេងៗគ្នាទៅដល់ឧស្សាហកម្មកាត់ដេរ។ ឯកសារទាំងនេះត្រូវបានកែសម្រួលពីមួយទៅមួយឆ្នាំ ដើម្បីបំពេញនូវតម្រូវការនៃឧស្សាហកម្មនេះ។

## ១. វគ្គត្រួតពិនិត្យការងារសម្រាប់អ្នកត្រួតពិនិត្យការងារ

ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារដែលមានរយៈពេល៤ថ្ងៃ ត្រូវបានរៀបចំឡើងសម្រាប់អ្នកត្រួតពិនិត្យការងារ ឬ មេការ។ការបណ្តុះបណ្តាលនេះផ្តល់ឱ្យនូវការយល់ដឹងយ៉ាងស៊ីជម្រៅពីភាពជាអ្នកដឹកនាំ និងគំនិតនៃការត្រួតពិនិត្យការងារ និងធ្វើឱ្យអ្នកត្រួតពិនិត្យការងារដើរតួនាទីយ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព។ ការបណ្តុះបណ្តាលនេះផ្តោតលើ :

- មូលដ្ឋានគ្រឹះនៃភាពជាអ្នកដឹកនាំ និងការត្រួតពិនិត្យការងារប្រកបដោយប្រសិទ្ធភាព
- ជំនាញប្រាស្រ័យទាក់ទងសម្រាប់ជាភាពជាអ្នកដឹកនាំនិងការត្រួតពិនិត្យការងារប្រកបដោយប្រសិទ្ធភាព

## ២. វគ្គត្រួតពិនិត្យការងារសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់

ដោយដឹងថាអ្នកគ្រប់គ្រងជាន់ខ្ពស់មិនមានពេលវេលាច្រើនគ្រប់គ្រាន់នោះ យើងបានរៀបចំនូវការបណ្តុះបណ្តាលមួយដែលមានរយៈពេលខ្លីនិងបញ្ចូលខ្លឹមសាររួមទាំងឡាយដោយដកស្រង់ចេញពីការបណ្តុះបណ្តាលមុនៗលើជំនាញផ្នែកត្រួតពិនិត្យការងារ។ ការបណ្តុះបណ្តាលនេះមានរយៈពេល២ថ្ងៃ ហើយគ្របដណ្តប់លើប្រធានបទដូចគ្នា ដោយសង្កត់ធ្ងន់លើការដោះស្រាយបញ្ហា។

## ៣. ការបណ្តុះបណ្តាលតាមប្រធានបទ

### *ផ្នែកកិច្ចសហការនៅកន្លែងធ្វើការ*

- វគ្គបណ្តុះបណ្តាលស្តីពីការណែនាំកម្មករដំបូងសម្រាប់អ្នកគ្រប់គ្រងធនធានមនុស្ស
- វគ្គជំនាញចរចា
- វគ្គកិច្ចសហការនៅកន្លែងធ្វើការ
- វគ្គណែនាំពីច្បាប់ការងារនៅកម្ពុជា

### *ផ្នែកសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ*

- វគ្គបណ្តុះបណ្តាលស្តីពីការសង្គ្រោះបឋម
- វគ្គសុខភាព និងសុវត្ថិភាពការងារ

### *ផ្នែកបរិបទចំរុះនៅកន្លែងធ្វើការ*

- វគ្គយល់ដឹងពីយេនឌ័រ
- វគ្គគ្រប់គ្រងវប្បធម៌ចំរុះនៅកន្លែងធ្វើការ
- វគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីពិការភាព

### *ផ្នែកបញ្ហាផលិតកម្ម*

- វគ្គគ្រប់គ្រងម៉ោងធ្វើការប្រកបដោយប្រសិទ្ធភាព
- វគ្គធ្វើឱ្យប្រសើរនូវល័ក្ខខ័ណ្ឌការងារ និងបន្តឱ្យកាន់តែប្រសើរ
- វគ្គគ្រប់គ្រងធនធានមនុស្ស និងល័ក្ខខ័ណ្ឌការងារ
- វគ្គគុណភាព
- វគ្គផលិតភាព

### *ផ្នែកការគ្រប់គ្រងបរិស្ថាន*

- វគ្គផលិតកម្មស្អាត

## ៤. វគ្គបណ្តុះបណ្តាលសម្រាប់កម្មករនិយោជិត

*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលផ្តោតលើកម្មករនិយោជិតកាត់ដេរ បានបង្កើតនូវកម្មវិធីបណ្តុះបណ្តាលមួយដែលធ្វើឡើងនៅតាមរោងចក្រកាត់ដេរនាំចេញ តាមរយៈការបញ្ចាំងខ្សែរវីដេអូអប់រំ។ នេះគឺជាកម្មវិធីបណ្តុះបណ្តាលលើកទី១ហើយនៅក្នុងប្រទេសកម្ពុជា ដែលមានបំណងដើម្បីបង្កើនចំណេះដឹងដល់កម្មករកាត់ដេរអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានផលិតនូវខ្សែរវីដេអូដ៏មានប្រជាប្រិយនេះ ចំនួន៨វគ្គដែលនិយាយអំពីៈ

- ការដោះស្រាយការកើតទុកមិនសុខចិត្ត
- ការដោះស្រាយវិវាទ និងកូដកម្មស្របច្បាប់
- ការលួច
- សុខភាព និងសុវត្ថិភាពការងារ
- ស្ត្រី និងការបំបៅដោះកូន
- កម្មករនិយោជិតមិនទាន់គ្រប់អាយុ /មិនចំណាយលុយដើម្បីបានការងារធ្វើ
- ការងារថែមម៉ោង
- ជំនាញបំណិនជីវិត

## ព័ត៌មានពាក់ព័ន្ធផ្សេងៗអំពីការបណ្តុះបណ្តាល

### *ការបណ្តុះបណ្តាលតាមតម្រូវការ*

*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ក៏បានផ្តល់ឱ្យនូវការបណ្តុះបណ្តាលតាមតម្រូវការ ដើម្បីបំពេញតម្រូវការជាក់លាក់របស់រោងចក្រនីមួយៗ។ រយៈពេលនៃការបណ្តុះបណ្តាលនេះ គឺផ្អែកទៅលើចំនួនអ្នកចូលរួម និងភាពស៊ីជម្រៅទៅលើប្រធានបទនីមួយៗ។

### *អ្នកចូលរួម*

ការបណ្តុះបណ្តាលរបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាគឺសំដៅទៅលើដៃគូពាក់ព័ន្ធនានានៅតាមរោងចក្រ។ ការបណ្តុះបណ្តាលរបស់យើង គឺរៀបចំឡើងសម្រាប់អ្នកគ្រប់គ្រង និងកម្មករនិយោជិត អ្នកដឹកនាំសហជីព ប្រតិភូបុគ្គលិក មន្ត្រីទំនាក់ទំនង និងតំណាងកម្មករ។

### *រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល*

ការបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដារត្រឹមត្រូវមានរយៈមួយថ្ងៃ ឬពីរថ្ងៃនៅក្នុងថ្នាក់រៀន។

### *ភាសា*

ការបណ្តុះបណ្តាលរបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* បង្រៀនជាភាសាខ្មែរដោយមានការបកប្រែជាភាសាអង់គ្លេស និងចិន អាស្រ័យតាមការសំណូមពរ។

### *កន្លែងបណ្តុះបណ្តាល*

ការបណ្តុះបណ្តាលអាចត្រូវបានធ្វើឡើងនៅតាមរោងចក្ររបស់អស់លោកអ្នក ឬនៅការិយាល័យនៃ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* ។

### *តម្លៃ*

- វគ្គបណ្តុះបណ្តាលដែលមានរយៈពេលមួយថ្ងៃ តម្លៃ ៣៥ដុល្លារក្នុងមួយនាក់
- វគ្គបណ្តុះបណ្តាលដែលមានរយៈពេលពីរថ្ងៃ តម្លៃ ៦៥ដុល្លារក្នុងមួយនាក់
- វគ្គបណ្តុះបណ្តាលអំពីជំនាញត្រួតពិនិត្យការងាររយៈពេលបួនថ្ងៃតម្លៃ ៦០ ដុល្លារ ក្នុងមួយនាក់ (មិនមានការផ្តល់ជូនអាហារថ្ងៃត្រង់ឡើយ)
- វគ្គបណ្តុះបណ្តាលកម្មករតាមរោងចក្រ

សូមទាក់ទងមកកាន់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*

### *តម្លៃនៃការបណ្តុះបណ្តាលរួមបញ្ចូលនូវ :*

- ការចូលរួមការបណ្តុះបណ្តាល ដែលបង្រៀនដោយគ្រូមានបទពិសោធន៍របស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*
- សំភារៈ និងឯកសារ
- អាហារថ្ងៃត្រង់ និងអាហារសំរន់
- វិញ្ញាបនបត្របញ្ជាក់ការសិក្សា

## សេវាប្រឹក្សា

ការធ្វើឱ្យប្រសើរនូវល័ក្ខខ័ណ្ឌការងារដើម្បីផលិតផលកាន់តែប្រសើរ តម្រូវឱ្យមានការផ្លាស់ប្រែនូវឥរិយាបថ និងអាកប្បកិរិយា ពីអ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងរោងចក្រ។ សេវាប្រឹក្សារបស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ថ្នាក់គ្រប់គ្រងរោងចក្រ និងកិច្ចខិតខំប្រឹងប្រែងរបស់តំណាងកម្មករនិយោជិត ដើម្បីឆ្ពោះទៅរកការប្រសើរឡើងជាបន្តបន្ទាប់។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ក្រុមការងារផ្នែកបណ្តុះបណ្តាល។